ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១៩១ សហវ.ហក

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០០៧

# ប្រកាសអន្តរក្រសួង
# ស្តីពីគោលការណ៍ចំណាយសំរាប់អនុវត្ត
# ថវិកាតាមកម្មវិធី នៅក្រសួងអប់រំ យុវជន និងកីឡា

************

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ .ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/ ០៧០៤ / ១២៤. ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រម លេខ ០១/ នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤. ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ ត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស / រកម/ ១២៩៩ / ១៥. ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់ស្តីពីវិសោធនកម្មមាត្រា ២៦ នៃច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២ /០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២ និងត្រូវបានកែប្រែដោយច្បាប់ ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ . ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និងប្រកាស លេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច នៃមាតិការថវិកាទូទៅរបស់រដ្ឋ

-បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ .ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីហិរញ្ញវត្ថុ សំរាប់គ្រប់គ្រងឆ្នាំ ២០០៧

-បានឃើញអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត-ក្រុង ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល របស់រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅ នៃគណនេយ្យសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញសារាចរណែនាំលេខ ០១៤ សហវ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការចំណាយតាមនីតិវិធីរជ្ជទេយ្យបុរេប្រទាន របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញសារាចរលេខ ០១៦ សហវ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការណែនាំលើការអនុវត្តថវិកាឆ្នាំ ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-បានឃើញតំរូវការចាំបាច់នៃការងារសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បច្ចុប្បន្ន

-អនុលោមតាមការចាំបាច់ និង ជាក់ស្តែងចំពោះមុខ

## សំរេច

## ជំពូកទី ១

## បទបញ្ញត្តិទូទៅ

**ប្រការ១ :** ក្រសួងអប់រំ យុវជន និង កីឡា ត្រូវមានភារកិច្ចរៀបចំគំរោង ផែនការ ថវិកាតាមកម្មវិធី និង គំរោងចំណាយថវិកា ដើម្បីធានាអោយការចំណាយមានតម្លាភាព គណនេយ្យភាព និង ប្រសិទ្ធភាពខ្ពស់ សំដៅ លើកកំពស់គុណភាពនៃការសិក្សាអប់រំ និង បណ្តុះបណ្តាលធនធានមនុស្ស ប្រកបដោយសមធម៌ ជាពិសេស ដើម្បី កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។

## ជំពូកទី ២

## គោលការណ៍ចំណាយ

**ប្រការ២ :** គោលការណ៍ចំណាយដោយឡែក ត្រូវបានកំណត់អោយអនុវត្ត សំរាប់ ថវិកាតាមកម្មវិធី ក្នុងការអភិវឌ្ឍលើវិស័យអប់រំ ដូចខាងក្រោម :

### ក- គុណភាព និងប្រសិទ្ធភាពនៃការអប់រំកុមារតូច

ផ្តល់ថវិកាសំរាប់ដំណើរការសាលាមត្តេយ្យរដ្ឋដែលមាន ៣កំរិត ចំនួនពី ២០០.០០០រៀល-៣០០.០០០រៀល ក្នុងមួយសាលា ។ ចំនួន ៦.០០០រៀល ក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សា (ថ្នាក់មត្តេយ្យរដ្ឋកំរិតខ្ពស់ដែលកុមារ មានអាយុប្រាំឆ្នាំ ទោះបីសាលាមត្តេយ្យនោះស្ថិតនៅក្រោមការគ្រប់គ្រង របស់សាលាបឋមសិក្សាក៏ដោយ) សំរាប់ចំណាយលើ:

-សំភារៈមូលដ្ឋាន

-ការកែលំអបរិស្ថាន សាលា និង ថ្នាក់រៀន

-ការជួសជុលតូច ( សង្ហារឹម បណ្ណាល័យ និងបរិក្ខារអេឡិចត្រូនិច )

-ចំណាយសំរាប់ទឹកស្អាត និងអនាម័យ

-ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក

-ចំណាយផ្សេងៗ ។

**ខ- គុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅបឋមសិក្សា**

១-ថវិកាសំរាប់ដំណើរការសាលារៀន

ផ្តល់ថវិកា ដល់គ្រប់សាលាបឋមសិក្សា ចំនួនពី ៥០០.០០០រៀល -៧០០.០០០រៀល ក្នុងមួយសាលា និងចំនួន ៧.០០០រៀល- ៨.០០០រៀល ក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សាសំរាប់ចំណាយលើ :

- សំភារៈមូលដ្ឋាន

-ការជួសជុលតូច ( សម្ភារីម បណ្ណាល័យ និងបរិក្ខារអេឡិចត្រូនិច )

-ការកែលំអបរិស្ថានសាលា និងថ្នាក់រៀន

-បំណិនជីវិត ( កីឡា សិល្បៈ រោងជាង គេហវិជ្ជា និង កសិកម្ម )

-ចំណាយសំរាប់ទឹកស្អាត និងអនាម័យ

-ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក

-ការរៀបចំឯកសារធ្វើតេស្តចុងឆ្នាំសិក្សា សំរាប់ថ្នាក់ទី ៣ និង ទី ៦

-ចំណាយផ្សេងៗ ។

២-ថវិកាសំរាប់ពង្រឹង គុណភាពរៀន និងបង្រៀន

-ផ្តល់ប្រាក់ឧបត្ថម្ភដល់ការប្រជុំនៅតាមកំរងសាលារៀន( ដើមឆ្នាំ កណ្តាលឆ្នាំ និង ចុងឆ្នាំ) ចំនួន ១១ពេល ក្នុងមួយឆ្នាំសិក្សា។

-ផ្តល់ប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀន ដែលបានបង្រៀនម៉ោងបន្ថែម សំរាប់ជួយសិស្ស នៅថ្ងៃព្រហស្បតិ៍ក្នុងឆ្នាំសិក្សា ចំនួន ១០.០០០រៀល ក្នុងមួយពេលក្នុងមួយនាក់ ដោយគិតទាំងអ្នកគ្រប់គ្រង បណ្ណារក្ស រោងជាង និងលេខាធិការ ។

**គ- គុណភាព និងប្រសិទ្ធភាពនៃការអប់រំនៅមធ្យមសិក្សា**

១-ផ្តល់ថវិកាសំរាប់ដំណើរការសាលារៀនចំនួនពី១.០០០.០០០រៀល-១.៥០០.០០០រៀល ក្នុងមួយសាលា ដល់គ្រប់អនុវិទ្យាល័យ និងវិទ្យាល័យ និងចំនួន ១៥.០០០រៀល - ១៨.០០០រៀល ក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សា សំរាប់ ចំណាយលើ :

- សំភារៈមូលដ្ឋាន

- ការកែលំអបរិស្ថានសាលារៀន និងថ្នាក់រៀន

- ការជួសជុលតូច ( សម្ភារីម បណ្ណាល័យ និងបរិក្ខារអេឡិចត្រូនិច )

8

- បំណិនជីវិត (កីឡា សិល្បៈ រោងជាង គេហវិជ្ជា និងកសិកម្ម)
- ការរៀបចំឯកសារ និង សំភារៈផ្សេងៗ សំរាប់ប្រលងឆមាស
- ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក
- ចំណាយផ្សេងៗ ។

២-ផ្តល់ថវិកាសំរាប់ប្រគល់រង្វាន់សិស្សពូកែប្រចាំឆ្នាំ ចំនួន ១០០.០០០រៀលក្នុងមួយថ្នាក់ក្នុងមួយឆ្នាំសិក្សា សំរាប់ចំណាយលើសំភារៈសិក្សា ។

## ឃ- គុណភាព និងប្រសិទ្ធភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ការរៀបចំស្តង់ដាតេស្ត ការទទួលស្គាល់កម្មវិធីសិក្សា និង មេរៀន ដោយអញ្ជើញអ្នកបច្ចេកទេសពីស្ថាប័នផ្សេង មកជួយហើយផ្តល់ជូន ១ជំនាញមាន ០២នាក់ចំនួន ១.០០០.០០០រៀល ក្នុងមួយក៏រិត ។

## ង- បន្តការអភិវឌ្ឍគ្រូបង្រៀន

១- ផ្តល់ថវិកាសំរាប់ដំណើរការសាលារៀនចំនួន ៣០.០០០.០០០រៀល ក្នុងមួយសាលាដល់ សាលាគរុកោសល្យ និងវិក្រឹតការខេត្ត-ក្រុង មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ និងសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈឹម ចំនួនពី១០០.០០០រៀល- ១២០.០០០រៀលក្នុងគរុសិស្ស-និស្សិតមួយនាក់ក្នុងមួយឆ្នាំសិក្សា សំរាប់ចំណាយលើ :

- សកម្មភាពបង្រៀន និង រៀន
- សកម្មភាពអប់រំសីលធម៌ និង មនសិការវិជ្ជាជីវៈ
- សកម្មភាពហ្វឹកហ្វឺនគរុកោសល្យ
- សកម្មភាពពលកម្មផលិត
- សកម្មភាពសិល្បៈ និង កីឡា
- សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រអប់រំ
- ចំណាយផ្សេងៗ:
  - +សំភារៈមូលដ្ឋាន
  - + ការជួសជុលតូច (សង្ហារឹម និងបរិក្ខារអេឡិចត្រូនិច)
  - +ការដឹកជញ្ជូន ការផ្គត់ផ្គង់សំភារៈ ។

២ -ការរៀបចំឯកសារធ្វើតេស្ត សំរាប់វាយតម្លៃសមត្ថភាពគ្រូឧទ្ទេសត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភដូចខាងក្រោម :

| | | |
|---|---|---|
| - ការកសាងតេស្ត | ឧបត្ថម្ភ | ១០០.០០០រៀល/ ១មុខវិជ្ជា |
| - ការធ្វើអត្រាកំណែ | ឧបត្ថម្ភ | ២០.០០០រៀល/ ១នាក់ |
| - កំរែកែកិច្ចការ | ឧបត្ថម្ភ | ២.០០០រៀល/ ១កិច្ចការ |

- គណៈកម្មការបូកសរុបលទ្ធផល ឧបត្ថម្ភ ៥០.០០០រៀល/ ១នាក់
- គណៈកម្មការត្រួតពិនិត្យ ឧបត្ថម្ភ ៣០.០០០រៀល/ ១នាក់
- អ្នកធ្វើរបាយការណ៍ ឧបត្ថម្ភ ៣០.០០០រៀល/ ១នាក់

ក្រសួងអប់រំ យុវជន និងកីឡា ត្រូវធ្វើសេចក្តីណែនាំស្តីពីការកំណត់និយាមរៀបចំគណៈកម្មការនីមួយៗ អោយបានច្បាស់លាស់ក្នុងករិតអប្បបរមា ។

**ច–** ចំពោះគ្រឹះស្ថាន ឬ មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ ដែលចប់ការគាំទ្រទាំងផ្នែកសំភារៈ និងថវិកាពីរដ្ឋាភិបាលបរទេស ឬ អង្គការអន្តរជាតិ នឹងទទួលបានការឧបត្ថម្ភថវិកាសំរាប់ដំណើរការសាលារៀន ចំនួន ៥០.០០០.០០០រៀល ក្នុងមួយសាលា និង ចំនួន ៥០០.០០០រៀល ក្នុងសិស្សមួយនាក់ ក្នុងមួយឆ្នាំសិក្សា សំរាប់ចំណាយលើៈ

- សំភារៈមូលដ្ឋាន
-ការជួសជុលតូច ( សង្ហារឹម និងបរិក្ខារអេឡិចត្រូនិច )
-សំភារៈកសិកម្ម រោងជាង និងបន្ទប់ពិសោធន៍
-ចំណាយទូទាត់ថ្លៃប្រើប្រាស់ថាមពលអគ្គិសនី និងទឹក
-ចំណាយផ្សេងៗ ។

**ឆ– គុណភាព និង ប្រសិទ្ធភាពនៃការបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា**

ផ្តល់ថវិកាសំរាប់ដំណើរការមជ្ឈមណ្ឌល ឬ សាលា ចំនួន ៣០.០០០.០០០រៀល ក្នុងមួយ មជ្ឈមណ្ឌល ឬសាលា និងចំនួន ១២០.០០០រៀល ក្នុងគរុសិស្សមួយនាក់ក្នុងមួយឆ្នាំសិក្សា សំរាប់ចំណាយលើៈ

- សកម្មភាពបង្រៀន និង រៀន
- សកម្មភាពហ្វឹកហ្វឺនគរុកោសល្យ
- សកម្មភាពបច្ចេកទេស និង ប្រកួត
- សកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្រកីឡា និង វេជ្ជសាស្ត្រកីឡា
- ចំណាយផ្សេងៗៈ
  +សំភារៈការិយាល័យ
  +ការជួសជុលទីលាន និង សំភារៈបច្ចេកទេសហ្វឹកហាត់
  +ការដឹកជញ្ជូន
  +ការផ្គត់ផ្គង់
  +ឯកសារសំរាប់ប្រជុំ ។

8

**ជ- ការពង្រឹងការអប់រំក្រៅប្រព័ន្ធ :**

ផ្តល់ថវិកាសំរាប់ដំណើរការ ថ្នាក់បំប៉នសិស្សបោះបង់ការសិក្សាចំនួនពី៥០.០០០រៀល-១០០.០០០រៀល ក្នុងមួយថ្នាក់ក្នុង ១ឆ្នាំ ( ខែសីហា និងកញ្ញា ) សំរាប់ចំណាយលើ : សៀវភៅ ប៊ិច ដីស ហ្វីតសរសេរ ក្តារខៀន ។ល ។

**ឈ- គោលការណ៍រួម និងដោយឡែក សំរាប់អនុវត្តគ្រប់អង្គភាពដែលបានទទួលថវិកាតាមកម្មវិធី :**

ការអនុវត្តថវិកាតាមកម្មវិធី និងការកសាងឯកសារបង្រៀន និងរៀនត្រូវបានផ្តល់ប្រាក់ឧបត្ថម្ភដូច ខាងក្រោម :

**១.គោលការណ៍រួម**

- ការថតចំលងឯកសារដោយមិនប្រើសំភារៈរបស់រដ្ឋ ទូទាត់ តាមតំលៃជាក់ស្តែង

| | | | |
|---|---|---|---|
| - ការវាយកុំព្យូទ័រ | ឧបត្ថម្ភ | ១.៥០០រៀល | ក្នុង១ទំព័រ |
| - អ្នកគូររូប | ឧបត្ថម្ភ | ១៦.០០០រៀល | ក្នុង១ទំព័រ |
| - ការបកប្រែឯកសារ | ឧបត្ថម្ភ | ៤.០០០រៀល | ក្នុង១ទំព័រវាយកុំព្យូទ័រ |
| - អ្នកនិពន្ធ | ឧបត្ថម្ភ | ១៤.០០០រៀល | ក្នុង១ទំព័រវាយកុំព្យូទ័រ |
| - ការផ្ទៀងផ្ទាត់ និង ត្រួតពិនិត្យ | ឧបត្ថម្ភ | ១.០០០រៀល | ក្នុង១ទំព័រវាយកុំព្យូទ័រ |
| - ការរៀបរៀង និង ចងក្រង | ឧបត្ថម្ភ | ៤.០០០រៀល | ក្នុង១ទំព័រវាយកុំព្យូទ័រ |
| - ការកែលំអមេរៀន | ឧបត្ថម្ភ | ១២.០០០រៀល | ក្នុង១មេរៀន |

**២.គោលការណ៍ដោយឡែកសំរាប់អនុវត្ត នៅតាមគ្រឹះស្ថានឧត្តមសិក្សា**

| | | | |
|---|---|---|---|
| - ការបកប្រែឯកសារ | ឧបត្ថម្ភ | ១២.០០០រៀល | ក្នុង១ទំព័រវាយកុំព្យូទ័រ |
| - អ្នកនិពន្ធ | ឧបត្ថម្ភ | ២៨.០០០រៀល | ក្នុង១ទំព័រវាយកុំព្យូទ័រ |
| -ការផ្ទៀងផ្ទាត់ និងត្រួតពិនិត្យ | ឧបត្ថម្ភ | ៤.០០០រៀល | ក្នុង១ទំព័រវាយកុំព្យូទ័រ |
| - ការកែលំអមេរៀន | ឧបត្ថម្ភ | ២០.០០០រៀល | ក្នុង១មួយមេរៀន |
| - ការជួលម៉ូដែល (Model) មនុស្សពិតមក ធ្វើគំរូ សំរាប់អោយនិស្សិតគូរតាម | ឧបត្ថម្ភ | ២០.០០០រៀល | ក្នុង១គំរូ ក្នុង១ពេល |

⊗ ចំពោះការទិញសំភារៈ និងឯកសារស្រាវជ្រាវផ្សេងៗពីបរទេស ត្រូវទូទាត់តាមសក្ខីបត្រជាក់ស្តែងតាមអត្រាប្តូរប្រាក់ជាផ្លូវការរបស់ធនាគារជាតិ ( ចំពោះតែសំភារៈនិងឯកសារណាដែលគ្មានលក់លើទីផ្សារក្នុងស្រុក ) ។

៥

## ជំពូក ៣
## ការអនុវត្តថវិកាតាមកម្មវិធី

**ប្រការ ៣ :** ក្រសួងអប់រំ យុវជន និងកីឡា ត្រូវតែងតាំងអាណាប័កផ្ទេរសិទ្ធិ និងផ្ទេរឥណទានថវិកាតាមកម្មវិធីជូន ទៅប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ដើម្បីទទួលខុសត្រូវក្នុងការគ្រប់គ្រង និងប្រើប្រាស់ឥណទានថវិកានេះ អោយទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ។ ចំពោះយន្តការដែលត្រូវអនុវត្តថវិកាតាមកម្មវិធីមានដូចខាងក្រោម:

-ឥណទានថវិកា សំរាប់ចំណាយដំណើរការថ្នាក់រៀន មជ្ឈមណ្ឌលសហគមន៍ សាលា គ្រឹះស្ថានសិក្សា និងការចំណាយថវិកាដែលមានគោលការណ៍កំណត់ច្បាស់លាស់ ត្រូវអនុវត្តតាមនីតិវិធីរជ្ជទេយ្យបុរេប្រទានមួយរយភាគរយ (១០០%) ដោយមិនគិត ១/៤ លើ ៣០ភាគរយនៃឥណទានដែលជ្រើសរើសមកបង្កើតរជ្ជទេយ្យបុរេប្រទាននេះទេ ។

- រាល់ការចំណាយថវិកាដែលពាក់ព័ន្ធទៅនឹងការទិញ ការជួសជុល ឬសេវាផ្សេងៗ ដែលមានទឹកប្រាក់ក្រោម **២០ លានរៀល** ត្រូវអនុវត្តតាមលំនាំនីតិវិធី នៃវិធីសាស្ត្រលទ្ធកម្ម "សួរថ្លៃ" ។

**ប្រការ ៤ :** ក្រោយពីមានប្រកាសអន្តរក្រសួង ស្តីពីការតែងតាំងរជ្ជទេយ្យករបុរេប្រទាន និងការបង្កើតរជ្ជទេយ្យបុរេប្រទានរួចមកក្រសួងអប់រំ យុវជន និងកីឡាត្រូវរៀបចំបែបបទនៃការដកសាច់ប្រាក់រជ្ជទេយ្យបុរេប្រទានដូចខាងក្រោម :

**- រដ្ឋបាលកណ្តាល :** ក្រសួងអប់រំ យុវជន និងកីឡា ត្រូវលើកសំណើសុំដកសាច់ប្រាក់ត្រង់ទៅរតនាគារជាតិតែម្តង

**- ខេត្ត-ក្រុង :** មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ត្រូវលើកសំណើសុំដកសាច់ប្រាក់ត្រង់ទៅរតនាគារខេត្ត-ក្រុង តែម្តង រួចរៀបចំបែងចែកសាច់ប្រាក់ជូនទៅ គ្រឹះស្ថានសិក្សា និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក- ខណ្ឌ ដើម្បីបន្តបើកផ្តល់ជូនសាលារៀន ។

**ប្រការ ៥ :** នីតិវិធី នៃការទូទាត់រជ្ជទេយ្យបុរេប្រទានត្រូវអនុវត្តតាមបរិបថដូចខាងក្រោម:

**- រដ្ឋបាលកណ្តាល :** គ្រប់អង្គភាពដែលអនុវត្តថវិកាតាមកម្មវិធីត្រូវប្រមូលសក្ខីប័ត្រចំណាយ និងលិខិតយុត្តិការ រៀបចំបោះផ្សាយអាណត្តិទូទាត់ ។ មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ដែលអមផ្ទាល់នៅក្រសួងអប់រំ យុវជន និងកីឡា មានសិទ្ធិពិនិត្យ និងចុះហត្ថលេខាលើអាណត្តិទូទាត់រជ្ជទេយ្យបុរេប្រទានក្នុងនាមជាអភិបាលហិរញ្ញវត្ថុ បន្ទាប់មកបញ្ជូនទៅរតនាគារជាតិ ។

- ខេត្ត-ក្រុង :

+ថ្នាក់រៀន មជ្ឈមណ្ឌលសហគមន៍ និងសាលារៀនត្រូវរៀបចំសក្ខីប័ត្រចំណាយ និងលិខិតយុត្តិការបញ្ជូនទៅ ការិយាល័យអប់រំ យុវជន និងកីឡាស្រុក - ខណ្ឌ ។ ការិយាល័យអប់រំ ស្រុក-ខណ្ឌត្រូវត្រួតពិនិត្យឯកសារទាំងអស់អោយបានត្រឹមត្រូវ និងបូកសរុប រួចបញ្ជូនបន្តទៅមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង

+គ្រឹះស្ថានសិក្សា ត្រូវរៀបចំប្រមូលសក្ខីប័ត្រចំណាយនិងលិខិតយុត្តិការបញ្ជូនទៅ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ។

ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត-ក្រុង ត្រូវពិនិត្យអោយបានត្រឹមត្រូវរាល់សក្ខីប័ត្រចំណាយ និងលិខិតយុត្តិការទាំងអស់ រួចរៀបចំបោះផ្សាយអាណត្តិទូទាត់ និងចុះហត្ថលេខា ដោយអាណាប័កផ្ទេរសិទ្ធិ បន្ទាប់មកបញ្ជូនអាណត្តិទូទាត់នោះ ទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត-ក្រុង ពិនិត្យ និងចុះហត្ថលេខាក្នុងនាមជាអភិបាលហិរញ្ញវត្ថុ មុននឹងបញ្ជូនទៅរតនាគារខេត្ត-ក្រុង ។

## ជំពូក៤

## អវសានបញ្ញត្តិ

**ប្រការ៦** : ប្រកាសនេះមានប្រសិទ្ធភាពចាប់ពីការអនុវត្តថវិកាតាមកម្មវិធីឆ្នាំ ២០០៧ តទៅ ។

**ប្រការ៧** : រាល់បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ៨** : គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និងក្រសួងអប់រំ យុវជន និង កីឡា មានភារកិច្ច អនុវត្តប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ ។

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ជ. ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**
**រដ្ឋលេខាធិការ**

អ៊ុំ_សិទ្ធិ

**កន្លែងទទួល :**

-អគ្គលេខាធិការព្រឹទ្ធសភា
-អគ្គលេខាធិការរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-អាជ្ញាធរសេវនកម្មជាតិ
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

-ដូចប្រការ ៨ "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ